**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

**សាលក្រមព្រហ្មទណ្ឌ**
លេខ ៧៦"ឈ"/៩៤០
ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ ១២៥៤
ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ១៧០
ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ៧០០
ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូង ខេត្តសៀមរាប

កាលបរិច្ឆេទនៃសវនាការជាសាធារណៈ ៖ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣
សាលសវនាការ និងពេលវេលា ៖ សាលលេខ ក១ នៅម៉ោង ៨:៣០ ព្រឹក
កាលបរិច្ឆេទនៃការប្រកាសសាលក្រម ៖ ថ្ងៃទី៧ ខែ ធ្នូ ឆ្នាំ២០២៣
សាលសវនាការ និងពេលវេលា ៖ សាលលេខ ក២ នៅម៉ោង ៩:៣០ ព្រឹក

ក្រោមសមាសភាពជំនុំជម្រះ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រម សាលាដំបូង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូង

**ដើម្បីធ្វើការពិភាក្សាដេញដោលលើ**

សំណុំរឿងព្រហ្មទណ្ឌលេខ ១២៥៤ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមានជនជាប់ចោទ៖

- ឈ្មោះ [redacted] **ពៅ** ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅភូ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៤ មុខរបរ លក់រថយន្ត ប្រពន្ធឈ្មោះ [redacted] **ស្រីខូច** មានកូន ៣នាក់ ឪពុកឈ្មោះ [redacted] **ងួន** (ស) ម្តាយឈ្មោះ [redacted] **នី**(រ) ទោសពីមុន គ្មាន (ក្នុងឃុំ រឿងផ្សេង)

*- ដីកាបង្គាប់ឱ្យចូលខ្លួនលេខ ៣០៦៧ ពស.ព្រស/ខ ចុះថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៣ ។*

*- ដីកាសម្រេចដាក់ជនត្រូវចោទស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៣៤២៦ ពស.ព្រស/ខ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៣ ។*

*- មេធាវី [redacted] ជាមេធាវីការពារសិទ្ធិ (វត្តមាន)*
*- មេធាវី [redacted] ជាមេធាវីការពារសិទ្ធិ (អវត្តមាន)*
*- មេធាវី [redacted] ជាមេធាវីការពារសិទ្ធិ (វត្តមាន)*



Scanned with CamScanner

ជននេះត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិស្វាយដង្គំ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់** ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

- ឈ្មោះ [redacted] **លីមឃីម** ភេទប្រុស អាយុ ៤៩ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប ។

- *មេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។*

- **បានឃើញ** ពាក្យបណ្តឹង ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] **លីមឃីម** ។

- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ **៥៨៩ អយយ** ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប ។

- **បានឃើញ** ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៤១៣៧ ពស.ព្រស/ខ** ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

- **បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ **៦៩២ ពស.ព្រជ(ក)** ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

**អង្គហេតុដែលប្តឹងមកតុលាការ**

កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ឈ្មោះ [redacted] **ពៅ** បានចេញមូលប្បទានបត្ររបស់ធនាគារ អេស៊ីលីដា លេខ ០៥៧០៨៩ មានទឹកប្រាក់ចំនួន ៤០.០០០(បួនម៉ឺន) ដុល្លារអាមេរិក ឱ្យមកឈ្មោះ [redacted] **លីមឃីម** ដើម្បីធ្វើការទូទាត់ប្រាក់ដែលឈ្មោះ [redacted] **ពៅ** ជំពាក់កន្លងមក ដោយមូលប្បទានបត្រនេះ តម្រូវឱ្យជនរងគ្រោះដកប្រាក់នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ តែដល់ថ្ងៃកំណត់ ជនរងគ្រោះទៅដកប្រាក់ស្រាប់តែខាងធនាគារ អេស៊ីលីដា ប្រាប់ថាមូលប្បទានបត្រខាងលើពុំមានសាច់ប្រាក់ បន្ទាប់មកជនរងគ្រោះបានទាក់ទងទៅឈ្មោះ [redacted] **ពៅ** ហើយឈ្មោះនេះចេះតែសុំពន្យារពេលរហូតដល់ពេលនេះ ។

**អំពីកិច្ចពិភាក្សាដេញដោលនាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] **ពៅ** បានឆ្លើយថា ឈ្មោះ [redacted] **លីមឃីម** នេះ ខ្លួនស្គាល់តាមរយៈឈ្មោះ [redacted] **ម៉េត** ដែលត្រូវជាមិត្តភក្តិរាប់អានគ្នា ។ ការពិតរឿងមូលប្បទានបត្រ(សែក)នោះ ដំបូងខ្លួនមិនមានចេញទេ ដោយខ្លួនដាក់តែឡានឲ្យគាត់ ([redacted] **លីមឃីម**)ទេ ដោយធ្វើក្រដាសលក់ទិញឲ្យគាត់ តែខ្លួនដាក់បញ្ចាំទេ តែឈ្មោះ [redacted] **លីមឃីម** ឲ្យខ្លួនធ្វើសែកដាក់បញ្ចាក់ ។ ឡាននោះដាក់ក្នុងតម្លៃ ១គ្រឿង ចំនួន ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក ហើយខ្លួនដាក់សែកឲ្យឈ្មោះ [redacted] **លីមឃីម** មិនមានសាច់ប្រាក់នោះទេ ហើយបើខ្លួនមិនធ្វើឲ្យគាត់ គាត់មិនឲ្យប្រាក់ ។ ខ្លួនមិនធ្លាប់ចេញសែកពីមុនមកទេ ។ ខ្លួនដាក់ឡានឲ្យគាត់ហើយដាក់សែកឲ្យគាត់ទៀត ។ ខ្លួនថាសែកនោះអត់មានលុយទេ ។ ខ្លួនស្គាល់សែក ហើយពីមុនមកមិនដែលធ្លាប់ចេញនោះទេ ។ សែកនោះរបស់ខ្លួន ហើយពីមុនមក ខ្លួនមិនដែលចេញ ហើយចេញជាមួយ [redacted] **លីមឃីម** ធ្លាប់ចេញ ។ ថ្ងៃដែលជួបគាត់ចេញលើកទី១ ។ លើកទី១ ខ្លួនដាក់ឡាន៥គ្រឿង ធ្វើក្រដាសលក់ទិញ និងធ្វើសែកអមជាមួយឲ្យគាត់ ទឹកប្រាក់ចំនួន ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ហើយសែក



Scanned with CamScanner

លេខ ០៥៧០៨៩ មានទឹកប្រាក់ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ហើយខ្លួនកាត់សាឡុងឲ្យគាត់តម្លៃ ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក ឲ្យគាត់និងការប្រាក់ ហើយសងគាត់បាន ១០.០០០(មួយម៉ឺន) ដុល្លារអាមេរិក ដោយនៅសល់ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ហើយគាត់បើអត់ធ្វើសែកថានៅជំពាក់គាត់ ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិកដដែល ។ ខ្លួនបញ្ជាក់គាត់ថា សែកនេះ អត់មានលុយនោះទេ ។ សែកនេះ ខ្លួនចេញសែកក្នុងគោលដៅដើម្បីទុកទូទាត់ជូនគាត់([redacted] **លឹមឃីម**) ។ ខ្លួនរៀនបានថ្នាក់ទី៤ ហើយរកស៊ីឡានជិត២០ឆ្នាំ ភាសាអង់គ្លេស មិនចេះ ចិន វៀតណាម និងភាសាផ្សេងទៀត ក៏ពុំចេះដែរ ។ ការចេញសែកឲ្យដើមបណ្ដឹងយកទៅបើកគ្មានប្រាក់ ហើយមានទោសខ្លួនដឹងដែរ តែដើមបណ្ដឹងជាអ្នកឲ្យខ្លួនចេញ ។ ខ្លួនបញ្ជាក់ជូនគាត់ហើយ ខ្លួនធ្វើដើម្បីទូទាត់លើកចុងក្រោយ ។ សែកនេះ ចេញលើកទី២ ដោយលើកទី១ ចំនួន ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ហើយលើកទី២ ចំនួន ៤០.០០០(បួនម៉ឺន) ដុល្លារអាមេរិក ហើយបើមិនធ្វើសែកលើកទី២ ថាខ្លួននៅជំពាក់ ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ។ ទើបពីដើមបណ្ដឹងបើកសែកអត់មានលុយហើយ ខ្លួនបានទៅចរចានៅសង្កាត់ ហើយសុំសងគាត់ ដកឡាន ចំនួន ១គ្រឿង តែគាត់មិនព្រមសុំយកឡានទាំងអស់ ។ ខ្លួនបញ្ជាក់គាត់ហើយថាសែកនោះអត់ទាន់មានលុយទេ ហើយគាត់នៅតែទាមទារឲ្យចេញទៀត ។ មកដល់ម៉ោងនេះ ខ្លួនមិនមានប្រាក់សងគាត់ទេ ។ ខ្លួនសុំសងគាត់ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ដោយសុំសងគាត់ ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក និងសុំយកឡានមកវិញ១គ្រឿង តែគាត់មិនព្រម ។ ចំពោះប្រាក់ជំពាក់ បើខ្លួនមាន ៥.០០០(ប្រាំពាន់) ដុល្លារអាមេរិក សងគាត់ ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិកសិន គាត់មិនព្រម ចង់បានប្រាក់ទាំងអស់ ។ សែកនោះ ខ្លួនប្រាប់ថាគ្មានលុយទេ ហើយខ្លួនថាកំពុងរៀបចំលុយ នៅធនាគារ ពេលបានលុយ ខ្លួននឹងសងគាត់ ។ ខ្លួនបញ្ជាក់ថាដាក់តែឡានទេ តែគាត់ឲ្យធ្វើសែក ដើម្បីទំនុកចិត្ត ។ មូលហេតុមុនដំបូងដែលខ្លួនបានចុះហត្ថលេខាចេញសែកនោះ ខ្លួនខ្ចីប្រាក់ពីឈ្មោះ [redacted] **លឹមឃីម** ចំនួន ៥០.០០០(ប្រាំម៉ឺន) ដុល្លារអាមេរិក និងមានកិច្ចសន្យា ដោយដាក់បញ្ចាំវត្ថុជាឡានចំនួន ៥គ្រឿង ដោយដាក់ឡាន ម៉ាក សាំយ៉ុង ចំនួន ១គ្រឿង កូរ៉ូឡា ចំនួន ១គ្រឿង ម៉ាក នីសាន់ ចំនួន ១គ្រឿង និងម៉ាក ឡិចស៊ីសចំនួន ២គ្រឿង ដោយមានកិច្ចសន្យា ដោយគាត់បង់ការប្រាក់ចំនួន ១០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក យក៥០០(ប្រាំរយ)ដុល្លារអាមេរិក ក្នុងមួយខែ ហើយខ្លួនបង់គាត់ជាសប្ដាហ៍ បាន៧ដង ហើយក្រោយមកសុំគាត់ពន្យារមកចំនួន២០ថ្ងៃ បង់បាន៣ដង ហើយសុំជាខែវិញ បង់បាន៤ដង ហើយខ្លួនពុំមានលុយបង់ប្រាក់ដើមទៅវិញទេ ហើយកាត់សាឡុងជាមួយប្រាក់ដើមអស់ចំនួន ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក ហើយខ្លួននៅជំពាក់គាត់ចំនួន ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិកវិញ ។ ចាប់ពីពេលនោះ ប្រហែល៤ទៅ៥ខែទៀត ខ្លួនស៊ូអត់បាន និងទៅអត់រួចហើយខ្លួនក៏ធ្លាប់ចរចាដែរ និងដោះស្រាយនៅសាលាឃុំ ។ ប្រាក់ចំនួន ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ដែលចេញសែកឲ្យក្រោយកាត់កងជាមួយសាឡុង ហើយខាងគាត់ទាមទារឲ្យខ្លួនចេញសែកឲ្យ ហើយខ្លួនថាសែកអត់មានលុយទេ ។ ឡានចំនួន ៥គ្រឿង ខ្លួនយកឡាន១គ្រឿង ម៉ាក សាំយ៉ុងចេញ ហើយគាត់ថា **ពៅ** ឯង មិនធ្វើសែកឲ្យ មិនឲ្យយកឡានចេញ និងវត្ថុបញ្ចាំនៅខាងដើមបណ្ដឹង ដើម្បីធានាលុយ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ។ ចំពោះសែក ខ្លួនចេញចំនួន ២ដង ដោយទឹកប្រាក់ ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិកម្ដង និងទឹកប្រាក់ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិកម្ដងទៀត ។ លុយចំនួន ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក នៅពេលខ្ចីលុយ អមជាមួយឡានដាក់បញ្ចាំ និងសែក ។ ខ្លួនជំពាក់គេច្រើន ហើយគាត់ក៏ដឹងដែរ ។ នៅថ្ងៃនោះ ខ្លួនយកឡានទៅដាក់ និង



Scanned with CamScanner

ទទួលលុយភ្លាមតែម្តង ។ ខ្លួនបានចេញសែកដើម្បីអមជាមួយការខ្ចីលុយ បើមិនចេញសែក មិនឲ្យលុយនោះទេ។ ខ្លួនធ្វើកិច្ចសន្យាខ្ចីប្រាក់ ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិកម្តង និង៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិកម្តងទៀត ដោយមានដាក់ឡានជានា ហើយចេញសែកអម ។ ឡានដាក់ជានាមានតម្លៃប្រហែល ៧០.០០០(ប្រាំពីរម៉ឺន)ដុល្លារអាមេរិក ហើយខ្លួនទទួលលុយសុទ្ធពីគាត់ចំនួន ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ហើយខាងដើមបណ្តឹងគាត់បានកាត់ការប្រាក់ចំនួន១ខែមុន ស្មើនឹង ២.៥០០(ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ដែលក្នុងនោះ ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក គាត់យកការប្រាក់ ៥០០(ប្រាំរយ) ដុល្លារអាមេរិក ។ បន្ទាប់មកខាងគាត់ទារលុយមិនបាន ក៏កាត់សាឡុង ហើយសាឡុងនោះលក់បានតម្លៃ ១៥.០០០(មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ហើយលុយដែលនៅសល់ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ហើយខ្លួនទូទាត់ប្រាក់៣ទៅ៤ខែ ហើយខ្លួនមិនចេះអក្សរទេ ហើយសែកនោះក្មួយរបស់ខ្លួនជាអ្នកសរសេរ ហើយខ្លួនបានផ្តិតមេដៃ ។ ខ្លួនពិតជាបាននិយាយសន្យាជាមួយខាងដើមបណ្តឹងថា បើខ្លួនសងប្រាក់ជារៀងរាល់ខែ មិនចាំបាច់សងប្រាក់ដើមមែន ។ ចំពោះការចែកសែកចំនួន ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ក្រោយពីកាត់សាឡុងក្នុងទឹកប្រាក់ ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិករួច ។ លុយ ៤០.០០០(បួនម៉ឺន) ដុល្លារអាមេរិក ជាប្រាក់ដើម ក្រោយកាត់សាឡុងហើយចំនួន ១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក និង ចំនួន ៥.០០០(ប្រាំពាន់)ដុល្លារអាមេរិក កាត់ថ្លៃការប្រាក់ ។ ខ្លួននិយាយថាចេះសរសេរ តែមិនចេះអាននោះទេ ហើយសរសេរក៏មិនត្រូវពេញតួអក្សរផងដែរ ។ ខ្លួនសុំបញ្ជាក់ថាកុំចោទប្រកាន់ខ្លួន ។

- ដើមបណ្តឹងឈ្មោះ [redacted] **លីមឃីម** បានឆ្លើយថា ខ្លួនអាយុ៥០ឆ្នាំ មុខរបរ ម៉ៅការសំណង់ ។ ឈ្មោះ [redacted] **ពៅ** ស្គាល់គាត់តាមរយៈឈ្មោះ [redacted] **សាម៉េត** ហើយឈ្មោះ [redacted] **ពៅ** ខ្ចីលុយខ្លួននៅខែកុម្ភៈ ឆ្នាំ ២០២២ ដោយដំបូង ឈ្មោះ [redacted] **ពៅ** ខ្ចីចំនួន ៥០.០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក ។ នៅចុងឆ្នាំ២០២១ ឈ្មោះ [redacted] **ពៅ** បានខ្ចីចំនួន ៨០.០០០ដុល្លារអាមេរិក បានចប់គ្នាហើយ ។ ប្រាក់ចំនួន ៨០.០០០(ប្រាំបីម៉ឺន)ដុល្លារអាមេរិក ដែលឈ្មោះ [redacted] **ពៅ** ខ្ចីនោះ បានដាក់ទ្រព្យជានា ហើយគាត់បានយកទៅដាក់កម្ចីបន្តនៅធនាគារ ។ ក្រោយមកឈ្មោះ [redacted] **ពៅ** បានខ្ចីប្រាក់ខ្លួនចំនួន ៥០.០០០ដុល្លារអាមេរិក ដើម្បីយកទៅដាក់នៅធនាគារដូចគ្នា ហើយសន្យា២០ថ្ងៃ គាត់សងខ្លួនវិញ ហើយការប្រាក់គិត ៥% ក្នុងរយៈពេល២០ថ្ងៃ លើប្រាក់ដើម ៥០.០០០ដុល្លារអាមេរិក ។ ខ្លួនប្រាប់គាត់ដែរថាប្រាក់នោះប្រើប្រាស់បានតែ ២០ថ្ងៃនោះទេ មិនអាចលើសនេះកើតទេ ។ ឈ្មោះ [redacted] **ពៅ** គាត់សន្យាសងប្រាក់វិញក្នុងរយៈពេល ២០ថ្ងៃ ហើយខ្លួនក៏បានឲ្យគេសរសេរសែកឲ្យ ហើយគាត់បានលុយហើយយកទៅដាក់ធនាគារ ។ ឈ្មោះ [redacted] **ពៅ** គាត់បានសរសេរសែក និងប្រគល់ជូនឲ្យខ្លួន នៅខែកុម្ភៈ ឆ្នាំ២០២២ ហើយត្រូវបើកប្រាក់នៅខែមីនា ឆ្នាំ ២០២២ ។ សែកខែមីនា គ្មានបញ្ហាទេ ដោយសារទូទាត់សងគ្នាចុះឡើង ។ សែកដែលមានបញ្ហា គឺត្រូវបើកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ។ សែកនោះឈ្មោះ [redacted] **ពៅ** ចេញជូននៅដើមខែមិថុនា ឆ្នាំ២០២២ ដោយមុនថ្ងៃទៅបើក ប្រហែល១៥ទៅ២០ថ្ងៃមុន ព្រោះគាត់សន្យាសងលុយបង្គ្រប់នៅថ្ងៃហ្នឹង ។ ឈ្មោះ [redacted] **ពៅ** ធ្លាប់បានចេញសែកជូនខ្លួនជាច្រើនលើកមកហើយ ។ គោលដៅដែលឈ្មោះ [redacted] **ពៅ** ចេញសែកឲ្យដើម្បីទូទាត់សងលុយ ។ សែកចេញក្នុងខែកុម្ភៈ ហើយបើកនៅខែមីនា ឆ្នាំ២០២២ ខ្លួនមិនបានទៅដកដល់ថ្ងៃភ្លាមៗទេ ហើយលើកទី១ មិនបានដកទេ ហើយលើកទី២ ខ្លួនទៅដក ហើយមិនបានឲ្យធនាគារចេញក្រដាស គាត់ចេះតែពន្យារពេលរហូត ហើយសែកលើកទី១ មិនមានលុយនោះទេ ។ សែកទី១ អត់មានបញ្ហា ដោយសារគាត់ចេះតែពន្យារពេល និងបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ហើយចែកសែកឲ្យថ្មី ហើយទៅ



Scanned with CamScanner

បើកនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ គ្មានលុយទេ ។ សែកគាត់ថាអត់មានសាច់ប្រាក់ តែគាត់សន្យាសងខ្លួននៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ អ៊ីចឹងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ គាត់មានលុយសងខ្លួនហើយ ។ សែកទឹកប្រាក់ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិក ឈ្មោះ [redacted] ពៅ បានចេញឲ្យក្រោយកាត់កងសាឡុងហើយមែន ដោយគាត់ចេះតែសុំពន្យារពេលសង ហើយខ្លួនក៏ទទួលយកសាឡុងនោះចុះ ដោយតម្លៃចំនួន ១០.០០០ដុល្លារអាមេរិក កាត់កងនឹងប្រាក់ជំពាក់ ៥០.០០០ដុល្លារអាមេរិក នៅសល់ ៤០.០០០ដុល្លារអាមេរិក ។ ឈ្មោះ [redacted] ពៅ បានចេញសែកឲ្យខ្លួនច្រើនលើក ។ ខ្លួនបានទៅបើកលុយនៅធនាគារម្ដង មុនធ្វើកិច្ចសន្យាថ្មីនិងចេញសែកនេះ តែធនាគារបញ្ជាក់ថាអត់មានសាច់ប្រាក់ តែមិនបានឲ្យធ្វើក្រដាសឲ្យទេ ។ ឈ្មោះ [redacted] ពៅ ចេញសែកឲ្យខ្លួន មិនចាំចំនួនដងនោះទេ ។ លើក១ មិនមានសាច់ប្រាក់ទេ លើកទី២ មិនមានសាច់ប្រាក់ និងលើកទី៣ ក៏អត់មានសាច់ប្រាក់ដែរ ។ ឈ្មោះ [redacted] ពៅ ខ្ចីប្រាក់ចំនួន ៥០.០០០ ដើម្បីបង់លុយនៅធនាគារ ដើម្បីបានកម្ចីមកវិញ ។ ខ្លួនអត់ច្បាស់រឿងបានលុយពីធនាគារចេញកម្ចីឲ្យគាត់មកវិញទេ ។ សែកចេញ អត់មានលុយ និងសែក នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ នៅតែអត់មានលុយ ។ លទ្ធភាពរបស់គាត់នៅតែអត់មាន ។ ខ្ចីប្រាក់ចំនួន ៥០.០០០ដុល្លារអាមេរិក មានធ្វើកិច្ចសន្យា ដោយដាក់ឡានបញ្ចាំ ៥គ្រឿង ។ ឡាន ៥គ្រឿង នោះនៅពេលកាត់កងសាឡុង ឈ្មោះ [redacted] ពៅ គាត់សុំដកយកវិញ ១គ្រឿង ។ រឿងលុយយកទៅ ខ្លួនបានប្រាប់ពីដើមទីថា ប្រើបានតែ ២០ថ្ងៃទេ ។ សែកចេញឲ្យដោយសារគាត់កំណត់ថ្ងៃសងប្រាក់ឲ្យខ្លួនវិញ ។ គាត់ចេញសែក និងថានៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ គាត់ទូទាត់សងលុយឲ្យខ្លួនវិញ ។ សែកដាក់ថាទិញអីវ៉ាន់ ជារឿងរបស់គាត់ ខ្លួនមិនបានមើលទេ ខ្លួនដឹងថារឿងជំពាក់ប្រាក់ ។ សែកគាត់ចេញផ្តិតមេដៃ ហើយក្មួយគាត់ជាអ្នកសរសេរឲ្យ ។ សែកនោះ ឈ្មោះ [redacted] ពៅ ចេញឲ្យកំណត់សងតែប្រាក់ដើម នៅដើមខែមិថុនា សែកទឹកប្រាក់ ៤០.០០០ដុល្លារអាមេរិក ហើយខ្លួនទៅបើកក្រោយថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ប្រហែល ២ទៅ៣ថ្ងៃ ។ គាត់សន្យាជាមួយខ្លួននៅថ្ងៃហ្នឹង គាត់សរសេរនៅថ្ងៃបើកនោះ ។ ខ្លួនសូមសំណូមពរទាមទារឲ្យឈ្មោះ [redacted] ពៅ ទី១. សងប្រាក់ ៤០.០០០ដុល្លារអាមេរិក ទី២ ការប្រាក់ ៥%(ប្រាំភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើម និងទី៣ បង់ជំងឺចិត្តចំនួន ៨០.០០០.០០០រៀល និងទី៤ សុំឲ្យតុលាការកាត់ទោសឈ្មោះ [redacted] ពៅ តាមច្បាប់ ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា ក្រោយពីធ្វើការពិភាក្សា និងសួរដេញដោលរួចមក ខ្លួនជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឲ្យលោកចៅក្រមផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសម្រេចតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសងប្រាក់ចំនួន៤០.០០០ដុល្លារអាមេរិក ទី២ ការប្រាក់ចំនួន ៥%(ប្រាំភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើម និងទី៣ បង់ជំងឺចិត្តចំនួន ៨០.០០០.០០០ រៀល និងទី៤ សុំឲ្យតុលាការកាត់ទោសឈ្មោះ [redacted] ពៅ តាមច្បាប់ ។

- លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានតបថា នៅក្នុងនោះដែរ ដូចយើងដឹងជាក់ស្តែងហើយ បើពិនិត្យទៅលើមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ចែងថាការចេញសែកយើងអត់មានលក្ខខណ្ឌនោះទេ ។ បើសិនជាយើងគិតថាវាអត់មានខុសច្បាប់អីនោះទេ តើមានជនប៉ុន្មាននាក់នឹងធ្វើការចេញសែកបែបនេះទៀត ។ សូមឲ្យលោកចៅក្រមពិចារណាលើរឿងនេះ ។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីធ្វើការពិភាក្សា និងសួរដេញដោលរួចមក ឃើញថា តំណាងអយ្យការសុំតម្កល់បទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ពី បទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ។ អំពើនេះ បំពានបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរ និងប្រតិបត្តិការទូទាត់សងប្រាក់ និងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះពិចារណានិងវិនិច្ឆ័យតាមច្បាប់ ។

តំណាងអយ្យការ ធ្វើសេចក្តីផ្ទានបន្ថែមថា ចង់បញ្ជាក់ថាមាត្រា ៣២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ រយៈពេលចេញសែក ក្នុងរយៈពេល៦ខែ ហើយបើរយៈពេលក្រោម៦ខែ អាចប្តឹងបាន បើលើស៦ខែ មិនអាចប្តឹងបានទេ ។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ៖ ផ្អែកតាមការពិភាក្សា និងសួរដេញដោលអំបាញ់មិញនេះ និងបញ្ជាក់រួចមកហើយថា អង្គហេតុទាំងអស់កើតចេញពីកិច្ចសន្យាខ្ចីប្រាក់ដោយមានដាក់ទ្រព្យបញ្ចាំផងដែរ ។ មុននេះបន្តិចកូនក្តីខ្លួនក៏បានបញ្ជាក់ផងដែរថា រហូតមកដល់ពេលនេះ ទ្រព្យបញ្ចាំនេះ មានតម្លៃហួសប្រាក់កម្ចីទៅទៀត ។ មិនត្រឹមតែប៉ុណ្ណោះទេ ក៏មានការទូទាត់សងទៅតាមកិច្ចសន្យាជាបន្តបន្ទាប់ ។ អ៊ីចឹង ទាក់ទងនឹងការចេញសែក និងដើមបណ្តឹងរដ្ឋប្បវេណីទទួលបានសែក គាត់បានដឹងថាកូនក្តីរបស់ខ្លួនអលទ្ធភាពរួចទៅហើយ គាត់ទទួលបានសែករហូតដល់៣ផង មានសែកទី១ សែកទី២ និងសែកទី៣ ហើយ ដើមបណ្តឹងរដ្ឋប្បវេណី ។ គាត់បានដឹងថាកូនក្តីរបស់ខ្លួនពិតជាអត់លទ្ធភាពក្នុងការសរសេរចេញសែកនោះទេ ។ អំបាញ់មិញ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថាការចេញសែកនេះប្រាកដជាគ្មានប្រាក់នោះទេ គាត់ដឹងថាអត់មានប្រាក់ហើយ គាត់នៅតែឲ្យចុះហត្ថលេខាចេញសែកទៀត ។ បានន័យថា គាត់ទទួលបានទ្រព្យបញ្ចាំផង និងសែកអមជាមួយផង ដើម្បីឲ្យគាត់មានសុវត្ថិភាព ក្នុងការទទួលបានប្រាក់ត្រឡប់ទៅវិញ ឲ្យគាត់សរសេរសែកឲ្យមួយទៀត ។ ដោយសារសែកនេះ មានការពេញនិយម ធ្វើឲ្យកូនបំណុលមួយចំនួន ទូទាត់សាច់ប្រាក់ មានការលំបាក និងការភ័យខ្លាចក្នុងការចុះហត្ថលេខាចេញសែក ។ បើចុះហត្ថលេខាលើសែក ដល់ថ្ងៃ អត់មានប្រាក់សង អាហ្នឹងត្រូវមានបញ្ហា ។ ដូច្នេះនៅក្នុងអារម្មណ៍បងប្អូនយើងទាំងអស់គ្នា ក្នុងការរស់នៅ ប្រកបអាជីវកម្ម ទំនាក់ទំនងសេដ្ឋកិច្ចតែងតែបារម្ភរឿងនេះ ។ ប៉ុន្តែអង្គហេតុទាំងអស់ ក៏ដូចជាសហភាគា ក៏បានបញ្ជាក់ផងដែរ អង្គហេតុទាំងអស់ផ្តើមចេញពីកិច្ចសន្យាខ្ចីប្រាក់ បានធ្វើការដោះស្រាយនៅសាលាឃុំផង និងបានដោះស្រាយវិវាទផ្សេងៗផង ហើយគាត់បានបញ្ជាក់ថានៅពេលខ្ចីលុយទៅដាក់ធនាគារនោះ មិនបានលុយពីធនាគារទេ អ៊ីចឹងគាត់ដឹងថាអត់បានប្រាក់ពីធនាគារ អត់បានប្រាក់យកទៅសងគាត់ហើយ គាត់នៅតែឲ្យចុះហត្ថលេខាចេញសែកទៀត បើអត់មានប្រាក់នោះទេ ។ ត្រឡប់មកវិញ ទាក់ទងនឹងចរិកលក្ខណៈនៃបទល្មើស ព្រោះអីក្រមព្រហ្មទណ្ឌរបស់យើង បានបញ្ជាក់អំពី ចរិកលក្ខណៈនៃការប្រព្រឹត្ត មុនពេលប្រព្រឹត្ត និងអំឡុងពេលក្នុងប្រព្រឹត្ត ។ អ៊ីចឹងបានន័យថានៅពេលចាប់ផ្តើមប្រព្រឹត្ត គឺគាត់យល់ថាការចុះហត្ថលេខាលើសែកនេះដើម្បីធានាកាតព្វកិច្ច ឬធានាទៅលើការសងទៅគាត់វិញ មិនមែនជាសែកចុះហត្ថលេខាដើម្បីទូទាត់នៅពេលណាមួយនោះទេ ។ ការទូទាត់ និងការធានា គឺខុសគ្នា ដោយការធានា ដូចធានាទៅលើកិច្ចសន្យាអ្វីមួយ ដោយឲ្យសែកទៅអ្នកណាមួយដើម្បីធានាសងនៅថ្ងៃអនាគត តែចំពោះការទូទាត់វាខុសគ្នា ។ អ៊ីចឹងច្បាប់បែងចែកច្បាស់ណាស់ថាចេតនានៃការប្រព្រឹត្តមានធាតុផ្សំទាំងបីនោះ ហើយអង្គហេតុទាំងអស់ បានបញ្ជាក់ ធាតុច្បាប់ មានហើយ ធាតុសម្ភារៈ



Scanned with CamScanner

មានហើយ ប៉ុន្តែនៅខ្វះធាតុមួយទៀត ជាគុសត្បានុម័ត ក្នុងការប្រព្រឹត្តបទល្មើស ព្រោះគាត់ចុះហត្ថលេខានៅលើសែកនោះ ដើម្បីជានាទៅលើបំណុលរបស់គាត់ទេ មិនមែនដើម្បីទូទាត់លើអីវ៉ាន់អីមួយ ឬទិញអីវ៉ាន់អីមួយមិនឲ្យលុយនោះទេ ។ ក្នុងនោះ សិទ្ធិរបស់ម្ចាស់បំណុលក៏មានសិទ្ធិផងដែរក្នុងការប្តឹងទៅរឿងរដ្ឋប្បវេណីអង្គសេចក្តី ដើម្បីរឹបអូសទ្រព្យសម្បត្តិដែលគាត់បានដាក់ជានាដើម្បីលក់ឡាយឡុងបាន ហើយដឹងតែបាន១០០% ទាំងប្រាក់ដើម ការប្រាក់ និងប្រាក់ផ្សេងៗទៀត ដែលស្ថិតនៅក្នុងផលប្រយោជន៍របស់ម្ចាស់បំណុល ។ ខ្លួនសូមឲ្យតុលាការពិចារណាលើធាតុផ្សំនៃបទល្មើសថាកូនក្តីរបស់ខ្លួនគ្មានចេតនាក្នុងការប្រព្រឹត្តបទល្មើស បើទោះបីមូលប្បទានបត្របានចេញហើយ តែចរិកលក្ខណៈនៃការប្រព្រឹត្តបទល្មើសគ្មានទេ ។ ចំពោះព្យសនកម្មដែលកើតមានចំពោះម្ចាស់បំណុល ក៏គ្មានដែរ ព្រោះគាត់មានទ្រព្យបញ្ចាំ ទ្រព្យជានាហើយ គាត់អាចទូទាត់ទៅលើបំណុលនោះទៅ ។ ខ្លួនសុំបញ្ជាក់ត្រង់ចំណុចនេះ ហើយខ្លួនសុំឲ្យតុលាការសម្រេចប្រានចោលការចោទប្រកាន់របស់តំណាងអយ្យការ និងក៏ដូចជាការប្តឹងរបស់ដើមបណ្តឹង ហើយកូនក្តីរបស់ខ្លួនពុំមានទោសបញ្ញត្តិណាមួយថាកូនក្តីរបស់ខ្លួនមានទោសនោះទេ ទាក់ទងនឹងមាត្រា ២៣១ នៃច្បាប់ស្តីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ហើយស្នើសុំបង្វិលសំណុំរឿងទៅរឿងរដ្ឋប្បវេណីវិញ ។

-លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ៖ ខ្លួនសុំបដិសេធចំពោះការចោទប្រកាន់លើកូនក្តីរបស់ខ្លួន ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន ព្រោះរឿងនេះកើតឡើងពីកិច្ចសន្យាខ្ចីចងការប្រាក់ ហើយកូនក្តីខ្លួនបានដាក់តម្កល់នូវឡានចំនួន ៥គ្រឿង ដែលមានតម្លៃជាង ៧០.០០០ដុល្លារអាមេរិក ក្នុងនោះដែរ ដើមបណ្តឹងរដ្ឋប្បវេណីគាត់បានឲ្យចេញសែកដើម្បីដាក់ជានាបំណុលផងដែរ ។ មិនត្រឹមតែប៉ុណ្ណោះខាងដើមបណ្តឹងឲ្យកូនក្តីខ្លួនធ្វើលិខិតលក់ទិញឲ្យស្របតាមកិច្ចសន្យាខ្ចីចងការប្រាក់ ត្រង់ប្រការ ៣.២ នៃកិច្ចសន្យា ដែលបានដាក់តម្កល់ទ្រព្យដែរនោះ។ ឃើញថា រឿងនេះមិនមានលក្ខណៈត្រឹមត្រូវសម្រាប់កូនក្តីរបស់ខ្លួននោះទេ ការប្តឹងរបស់ដើមបណ្តឹង បានលើកឡើងត្រឹមតែមូលប្បទានបត្រចំនួន ១សន្លឹក ដែលកូនក្តីរបស់ខ្លួនបានចេញឲ្យ ហើយពុំបានរៀបរាប់ដំណើររឿងឲ្យបានគ្រប់ជ្រុងជ្រោយអំពីការចេញសែកនោះទេ ដែលបានបញ្ជាក់ថាកូនក្តីខ្លួនគ្រាន់តែខ្ចីប្រាក់តែប៉ុណ្ណោះ និងដាក់ជានាលើបំណុលនូវឡានចំនួន ៥គ្រឿងដែលមានតម្លៃជាង ៧០.០០០ដុល្លារអាមេរិក និងសែកដើម្បីជានាលើបំណុល ។ ផ្អែកតាមបញ្ញត្តិមាត្រា ៣២ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ចែងថា *មូលប្បទានប័ត្រ ត្រូវតែបានបង្ហាញដើម្បីឲ្យទូទាត់សងប្រាក់ក្នុងរយៈពេលប្រាំមួយ(៦)ខែ គិតពីថ្ងៃចេញផ្សាយ* ។ បើពិនិត្យទៅលើការបញ្ជាក់របស់ធនាគារលើសែក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ មិនទាន់មានរយៈពេល៦ខែនោះទេ ។ ដូច្នេះ ឃើញថា កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់ដើមបណ្តឹងនោះ ។ ខ្លួនសំណូមពរសុំឲ្យលោកចៅក្រមពិចារណានិងសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ ។

- លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានបន្ថែមថា ខ្លួនសូមបញ្ជាក់ជូនថាសែកដែលកូនក្តីរបស់ខ្លួនចេញ ដើម្បីជានាលើបំណុល មិនមែនជានាលើការទូទាត់កាតព្វកិច្ចនោះទេ ។ ការជានាលើបំណុល ដូចកិច្ចសន្យាមានអ៊ីចឹងឯង ព្រោះច្បាប់ចែង ពាក់ព័ន្ធនឹងមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ការចេញមូលប្បទានប័ត្រគ្មានសាច់ប្រាក់ផ្តន្ទាទោសតាមច្បាប់ ។ ប៉ុន្តែនៅក្នុងច្បាប់ពិសេស យើងក៏ត្រូវបកស្រាយយោងក្រមព្រហ្មទណ្ឌ ដែរ អំពីចរិកលក្ខណៈនៃ

ការប្រព្រឹត្តបទល្មើសផងដែរ ។ ដូច្នេះខ្លួននៅតែសុំឲ្យតុលាការពិចារណាច្រានចោលការប្តឹងសុំរបស់ដើមបណ្តឹង ។

## **សំដីចុងក្រោយរបស់ជនជាប់ចោទ**

- ជនជាប់ចោទឈ្មោះ [redacted] ពៅ សំណូមពរសុំតុលាការកុំឲ្យចោទប្រកាន់លើរូបខ្លួន ។
- **ក្រោយពី** បានស្តាប់ចម្លើយរបស់ជនជាប់ចោទ
- **ក្រោយពី** បានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- **ក្រោយពី** បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី
- **ក្រោយពី** បានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- **ក្រោយពី** បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
- **ក្រោយពី** បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ
- **ក្រោយពី** បានពិនិត្យលើភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

## **ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

## **សំអាងហេតុ**

១- សាលាដំបូងខេត្តសៀមរាប បានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ **១២៥៤** ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលមានជនជាប់ចោទឈ្មោះ [redacted] **ពៅ** ភេទប្រុស អាយុ៤៥ឆ្នាំ ដែលត្រូវបានបញ្ជូនមកជំនុំជម្រះ ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិស្វាយដង្គំ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២៣១** នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។ តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៤១៣៧ ពស.ព្រស/ខ** ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប និងតាមមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឱ្យសាលាដំបូងខេត្តសៀមរាប មានសមត្ថកិច្ចក្នុងការជំនុំជម្រះ ។

២- តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៤១៣៧ ពស.ព្រស/ខ** ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ដែនកំណត់នៃការប្តឹងមកតុលាការ ចំពោះអង្គហេតុ តាមមាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងដែនកំណត់នៃការប្តឹងមកតុលាការ ចំពោះបុគ្គល តាមមាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឱ្យសាលាដំបូងខេត្តសៀមរាបមានសមត្ថកិច្ចក្នុងការជំនុំជម្រះលើអង្គហេតុដែលប្តឹងមកតុលាការ និងចំពោះជនជាប់ចោទឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ៤៥ឆ្នាំ ដូចមានអត្តសញ្ញាណខាងលើ ។

៣- ចម្លើយរបស់សារភាពរបស់ជនជាប់ចោទនៅចំពោះអង្គសវនាការថា ខ្លួនចេញមូលប្បទានបត្រ(សែក)ដែលមានទឹកប្រាក់ ៤០.០០០(បួនម៉ឺន)ដុល្លារអាមេរិកនេះ ក្នុងគោលដៅដើម្បីទុកទូទាត់លុយជូនដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **លីមឃីម** ហើយចម្លើយរបស់ជនជាប់ចោទរូបនេះ ក៏មានភាពស៊ីសង្វាក់គ្នានឹងចម្លើយរបស់ដើមបណ្តឹងរដប្បវេណី មូលប្បទានបត្រ(សែក)របស់ធនាគារ អេស៊ីលីដា លេខ ០៥៧០៨៩ មានទឹកប្រាក់ចំនួន **៤០.០០០**(បួនម៉ឺន) និងភស្តុតាងទាំងឡាយក្នុងសំណុំរឿង ដែលបានបង្ហាញឱ្យឃើញថា នៅដើមខែមិថុនា ឆ្នាំ២០២៣ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **លីមឃីម** ពិតជាបានទទួលសែកខាងលើពីជនជាប់ចោទឈ្មោះ [redacted] **ពៅ** ក្នុងទំហំទឹកប្រាក់ ៤០.០០០(បួនម៉ឺន) ដុល្លារអាមេរិក



Scanned with CamScanner

ដែលតាមរយៈសែកនេះ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **លឹមឃីម** ត្រូវទៅបើកប្រាក់ចំនួន ៤០.០០០ (បួនម៉ឺន)ដុល្លារអាមេរិក នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ប៉ុន្តែនៅពេលយកសែកនោះទៅបើកប្រាក់នៅធនាគារ ខាងធនាគារបញ្ជាក់ថា សែកនេះពិតជាអត់មានសាច់ប្រាក់ប្រាកដមែន ។

៤- ជនជាប់ចោទជានីតិជន និងមានមេធាវីការពារសិទ្ធិតាមផ្លូវច្បាប់ហើយ និងពុំមានសញ្ញាណាមួយនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ដូច្នេះជនជាប់ចោទត្រូវតែទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួនក្នុងកម្រិតច្បាប់បានកំណត់ ។

៥- ជនជាប់ចោទ មានចេតនាទុច្ចរិតធ្វើឲ្យខូចប្រយោជន៍ដល់ជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការចាត់ចែងយកសែកដែលដាក់ចំនួនទឹកប្រាក់ និងកាលបរិច្ឆេទកំណត់ត្រូវបើកប្រាក់ដើម្បីទូទាត់សងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណី ដែលដល់ថ្ងៃកំណត់ត្រូវដកប្រាក់ មិនមានទឹកប្រាក់នោះទេ ដែលច្បាប់បញ្ញត្តថាជាបទល្មើស និងត្រូវផ្តន្ទាទោស ។

៦- អំពើរបស់ជនជាប់ចោទបានប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គម ។

៧- តាមការពិនិត្យ និងវាយតម្លៃលើភស្តុតាងទាំងឡាយក្នុងសំណុំរឿង និងចម្លើយរបស់ជនជាប់ចោទទាក់ទិន អង្គហេតុដែលបានប្តឹងចោទប្រកាន់ និងបញ្ជូនមកជំនុំជម្រះនេះ មានភាពច្បាស់លាស់ និងមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ និងលើសពីវិមតិសង្ស័យ បង្ហាញថាជនជាប់ចោទឈ្មោះ [redacted] **ពៅ** មានពិរុទ្ធភាព ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិស្វាយដង្គំ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់** ដែលគប្បីតុលាការសម្រេចផ្តន្ទាទោសតាមច្បាប់ ។

៨- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលមានខ្លឹមសារជាគោលថា ស្នើសុំឲ្យលោកចៅក្រមផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសម្រេចតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុំទាមទារប្រាក់ចំនួន ៤០.០០០ដុល្លារអាមេរិក ទី២ ការប្រាក់ចំនួន ៥%(ប្រាំភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើម និងទី៣ បង់ជំងឺចិត្តចំនួន ៨០.០០០.០០០រៀល ។ ***ឃើញថា*** តាមសំអាងហេតុខាងលើ សេចក្តីសន្និដ្ឋានការពារនេះ មានមូលដ្ឋាន និងមូលហេតុសមហេតុផល ដែលតុលាការគប្បីពិនិត្យ ពិចារណា និងសម្រេច តាមមូលដ្ឋាន សំអាងហេតុខាងលើ ភស្តុតាង និងនីតិវិធីជាធរមាន ។

៩- សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ សុំតម្កល់បទចោទប្រកាន់លើជនជាប់ចោទឈ្មោះ **ងួន ពៅ** ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍ដែលអាចជួញដូរ និងប្រតិបត្តិការទូទាត់សងប្រាក់ និងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះពិចារណា និងវិនិច្ឆ័យតាមច្បាប់ ។ ***ឃើញថា*** តាមសេចក្តីសន្និដ្ឋានប្តឹងសុំនេះ តុលាការគប្បីពិនិត្យ ពិចារណា និងសម្រេច តាមមូលដ្ឋានសំអាងហេតុខាងលើ ភស្តុតាង និងនីតិវិធីជាធរមាន ។

១០- សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ដែលមានខ្លឹមសារជាគោលថា កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងអយ្យការនោះទេ ហើយកូនក្តីខ្លួនចេញមូលប្បទានបត្រ(សែក)ដើម្បីទុកជានាការខ្ចីប្រាក់ដាក់បញ្ចាំទ្រព្យតែប៉ុណ្ណោះ មិន



Scanned with CamScanner

ចេញសែកដើម្បីទូទាត់សងប្រាក់ទៅដើមបណ្តឹងរដ្ឋប្បវេណីឡើយ ហើយសំណូមពរសុំឲ្យលោកចៅក្រមពិចារណានិងឲ្យកូនក្តីខ្លួនរួចផុតពីបទចោទ ។ ***ឃើញថា*** តាមសេចក្តីសន្និដ្ឋានស្នើសុំនេះ មិនមូលហេតុនិងមូលដ្ឋានផ្លូវច្បាប់ និងអង្គហេតុ ដែលអាចតុលាការឲ្យតុលាការជឿបាននោះទេ ដោយហេតុថាតុលាការបានផ្តល់ជាមូលដ្ឋានសំអាងហេតុខាងលើ ភស្តុតាង និងរកឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដែលតុលាការគប្បីសម្រេចតាមនីតិវិធីជាធរមាន ។

១១- សំអាងហេតុ និងមូលហេតុដែលជាមូលដ្ឋាននៃការប្តឹងចោទប្រកាន់ និងការបញ្ជូនមកជំនុំជម្រះ ក្នុងដីកាសន្និដ្ឋានស្ថាពរលេខ **៥៨៩ អយយ** ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប និងដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៤១៣៧ ពស.ព្រស/ខ** ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប មានភាពត្រឹមត្រូវគ្រប់គ្រាន់ តាមមូលដ្ឋាន អង្គហេតុ ភស្តុតាង ដែលគប្បីតុលាការពិនិត្យ ពិចារណា និងសម្រេច តាមភស្តុតាងជាក់ស្តែង ។

**១២-** ភាគីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **លីមឃីម** បានសំណូមពរសុំទាមទារឲ្យឈ្មោះ [redacted] **ពៅ** សងប្រាក់ចំនួន ៤០.០០០ដុល្លារអាមេរិក ទី២ ការប្រាក់ចំនួន ៥%(ប្រាំភាគរយ) ក្នុងមួយឆ្នាំនៃប្រាក់ដើម និងទី៣ បង់ជំងឺចិត្តចំនួន ៨០.០០០.០០០រៀល និងសុំឲ្យតុលាការកាត់ទោសគាត់តាមច្បាប់ ដែលផ្អែកតាមសំអាងហេតុខាងលើ តុលាការគប្បីពិនិត្យ ពិចារណា និងសម្រេចលើផ្នែកសំណងរដ្ឋប្បវេណី ដោយផ្អែកលើអង្គហេតុ ព្យសនកម្ម និងភាពសមហេតុសមផល ។

## ហេតុដូច្នេះសម្រេច

១- ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] **ពៅ** ភេទប្រុស អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) (**ក្នុងឃុំ**) ដាក់ពន្ធនាគារកំណត់ **១(មួយ)ឆ្នាំ**

ពីបទ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅភូមិស្វាយដង្គំ សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា **២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់** ។

២- ឲ្យឈ្មោះ [redacted] **ពៅ** សងសំណងការខូចខាតចំនួន **៤០.០០០(បួនម៉ឺន)**ដុល្លារអាមេរិក និងជំងឺចិត្តចំនួន **១០.០០០.០០០(ដប់លាន)**រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **លីមឃីម** ។ ច្រានចោលការទាមទារលើសពីនេះ ។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈ នៅថ្ងៃទី**៧** ខែ**ធ្នូ** ឆ្នាំ**២០២៣** ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ខេត្តសៀមរាប ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៣

បានឃើញ
**ចៅក្រមជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner